ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ........................................................

# សុន្ទរកថា

## ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា ថ្លែងក្នុងឱកាស អបអរសាទរខួបអនុស្សាវរីយ៍លើកទី១០៤ នៃទិវានារីអន្តរជាតិ ៨ មីនា ឆ្នាំ២០១៥

**រាជធានីភ្នំពេញ ថ្ងៃទី៦ ខែមីនា ឆ្នាំ២០១៥**

**សូមគោរព ៖**

- **លោកជំទាវ ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា**
- **ឯកឧត្តម លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំ និងបងប្អូននារីនៃធនាគារជាតិនៃកម្ពុជា ទាំងអស់ ជាទីមេត្រី**

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយជាអនេក ដោយបានមកចូលរួមជាមួយ លោកជំទាវ ឯកឧត្តម លោក លោកស្រី និងនាងកញ្ញា ក្នុងពិធីអបអរសាទរខួបអនុស្សាវរីយ៍ លើកទី១០៤ ទិវានារីអន្តរជាតិ ៨ មីនា ឆ្នាំ២០១៥ សម្រាប់មន្ត្រីបុគ្គលិករបស់ធនាគារ ជាតិនៃកម្ពុជា ។ ពិធីឆ្នាំនេះ ត្រូវបានប្រារព្ធធ្វើឡើងក្រោមប្រធានបទ **"ដំណើរឆ្ពោះទៅមុខៈ ស្ត្រីកម្ពុជាក្រោយសន្និសីទស្ត្រីពិភពលោកឆ្នាំ១៩៩៥"** ដើម្បីរំឭកពីប្រវត្តិនៃការតស៊ូ និងវីរភាព របស់នារី ដែលបានខិតខំតស៊ូទាមទារនូវសមធម៌ ការគោរពសិទ្ធិសេរីភាពស្មើគ្នាចំពោះ មុខច្បាប់ និងការទទួលស្គាល់តម្លៃស្ត្រីក្នុងការអភិវឌ្ឍគ្រួសារ សង្គម និងប្រទេសជាតិ នាពេលកន្លងមក ។ ម្យ៉ាងទៀតប្រធានបទឆ្នាំនេះ ក៏បង្ហាញពីស្មារតីក្នុងការជម្រុញតួនាទី ស្ត្រីកម្ពុជា រួមគ្នាជម្នះរាល់ឧបសគ្គទាំងឡាយ ដើម្បីឆ្ពោះទៅកសាងប្រទេសជាតិមួយ មានសន្តិសុខ ស្ថិរភាព ប្រជាធិបតេយ្យ និងការអភិវឌ្ឍឈានឡើង ដែលផ្តើមចេញពី ធនធានមនុស្សប្រកបដោយគុណវឌ្ឍិ ហើយរួមចំណែកដល់ការអភិវឌ្ឍប្រកបដោយ ចីរភាព ។ ធនាគារជាតិនៃកម្ពុជាយើងតែងតែប្រារព្ធពិធីនេះជារៀងរាល់ឆ្នាំ ដើម្បីលើក កម្ពស់ និងថ្លែងអំណរគុណចំពោះថ្នាក់ដឹកនាំ និងមន្ត្រីបុគ្គលិកជានារីនៅធនាគារជាតិ នៃកម្ពុជា ដែលបានរួមចំណែកកសាងនិងអភិវឌ្ឍប្រព័ន្ធធនាគារនៅកម្ពុជា ។



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ថ្ងៃនេះ ខ្ញុំសង្កេតឃើញថា បងប្អូននារីយើងមានទឹកមុខរីករាយ ស្រស់ថ្លា និង ញញឹម ញញែមប្រកបដោយសេចក្ដីសង្ឃឹមជានិច្ច ។ ខ្ញុំសូមចូលរួមអបអរសាទរយ៉ាង ខ្លាំងក្លាចំពោះ ស្នាដៃនារី និងសូមប្រសិទ្ធពរជ័យ បវរសួស្ដី វិបុលសុខ មហាប្រសើរ គ្រប់យ៉ាង ចំពោះ លោកជំទាវ ថ្នាក់ដឹកនាំ និងបងប្អូននារីធនាគារជាតិនៃកម្ពុជាទាំងអស់ សមប្រកបដោយ កាយពលរឹងមាំ ប្រាជ្ញាវាងវៃ សុខភាពល្អ និងទទួលបានជ័យជម្នះ គ្រប់ភារកិច្ច ។

**- គណៈអធិបតី ជាទីគោរព !**

**- បងប្អូននារីទាំងអស់ ជាទីស្នេហា !**

ឆ្លៀតក្នុងឱកាសដ៏វិសេសវិសាលនេះ ខ្ញុំសូមជម្រាបពីប្រវត្តិនិងវីរភាពនៃការតស៊ូ របស់នារី ការទទួលខុសត្រូវ និងតម្លៃនារីនៅក្នុងគ្រួសារ សង្គម និងការងារក្នុងឆាក នយោបាយ ដើម្បីរួមចំណែកអភិវឌ្ឍប្រទេសជាតិ ដូចខាងក្រោម ៖

ជាប្រវត្តិនៃទិវា ៨ មីនា គឺផ្ដើមចេញពីការតស៊ូយ៉ាងស្វិតស្វាញរបស់ស្ត្រី នៅក្រុង ស៊ីកាហ្គោ និងញូយ៉ក សហរដ្ឋអាមេរិក ដែលបានសាមគ្គីគ្នាក្រោកឈរតស៊ូយ៉ាងប្តូរផ្តាច់ ទាមទារឲ្យបន្ថយម៉ោងធ្វើការនិងតម្លើងប្រាក់បៀវត្សនាថ្ងៃទី៨ ខែមីនា ឆ្នាំ១៨៩៩ ។ ដូចនេះហើយ ជារៀងរាល់ឆ្នាំ នៅលើពិភពលោកស្ទើរតែគ្រប់ប្រទេសទាំងអស់ តែងតែ រៀបចំពិធីអបអរសាទរទិវាអន្តរជាតិនារី ៨ មីនា ដើម្បីរំឭកឡើងវិញនូវវីរភាពរបស់នារី ដែលបានតស៊ូ វើបម្រះ និងពុះពារគ្រប់ឧបសគ្គ ដើម្បីរំដោះខ្លួនចេញពីការជិះជាន់ និង ការរើសអើងនៅក្នុងសង្គម រហូតដល់សម្រេចបានជោគជ័យ និងបានធ្វើឱ្យមានសមភាព រវាងបុរសនិងស្ត្រី ទាំងក្នុងការបញ្ចេញមតិយោបល់ និងការទទួលបានប្រាក់បៀវត្សដូចគ្នា ចំពោះការងារដូចគ្នាជាដើម ។ បន្ទាប់មក បញ្ហាដែលពាក់ព័ន្ធនឹងស្ត្រីបានក្លាយជា ប្រធានបទយ៉ាងសំខាន់ សម្រាប់កិច្ចពិភាក្សា នៅលើវេទិកាជាតិ និងអន្តរជាតិ ហើយ តួនាទីរបស់ស្ត្រីកាន់តែត្រូវបានទទួលស្គាល់ និងលើកកម្ពស់ជាលំដាប់ តាមរយៈ ការជំរុញឱ្យស្ត្រីចូលរួមនៅក្នុងការងារសង្គម សេដ្ឋកិច្ច និងនយោបាយ និងការផ្ដល់ អាទិភាពចំពោះស្ត្រីនៅក្នុងការអភិវឌ្ឍធនធានមនុស្ស ។ល។

នៅប្រទេសកម្ពុជាវិញ បើតាមប្រវត្តិសាស្ត្របានបញ្ជាក់ថា ស្ត្រីមានសារៈសំខាន់ ណាស់ ចំពោះសង្គមនិងគ្រួសារ ។ ព្រះនាងលីវយី គឺជាព្រះមហាក្សត្រីយានី និងជា ស្ត្រីទី១ ដែលគ្រប់គ្រងនិងដឹកនាំប្រទេសកម្ពុជា ។ បន្ទាប់មក នៅសម័យអង្គរ ព្រះនាង ឥន្ទ្រទេវី ជាអគ្គមហេសី ព្រះបាទជ័យវរ្ម័នទី៧ និងជាស្ត្រីដែលមានប្រាជ្ញាឈ្លាសវៃ បាន

ជួយការងារសង្គម និងបានជ្រោមជ្រែង **ព្រះបាទជ័យវរ្ម័នទី៧** ជាស្វាមី ដឹកនាំ ប្រទេសកម្ពុជាទទួលបានជោគជ័យ និងមានកេរ្តិ៍ឈ្មោះល្បីរន្ទឺ ក្នុងប្រវត្តិសាស្ត្រកម្ពុជារហូតមកដល់សព្វថ្ងៃនេះ ។ ចំណែកឯ ក្នុងរឿងព្រេងខ្មែរយើងវិញ យើងមាន រឿងមាយើង ដែលចៅមាណពមានប្រពន្ធជាស្ត្រីគ្រប់លក្ខណ៍ នាំឲ្យគ្រួសារនោះបានថ្កុំថ្កើនរុងរឿង ។ ហើយរឿងមាយាស្ត្រី ក៏បង្ហាញពីតួនាទីស្ត្រីដែលមានភាពឈ្លាសវៃ អាចដោះស្រាយលើគ្រប់បញ្ហាដោយប្រាជ្ញាវាងវៃរបស់គាត់ ព្រមទាំងបាននាំសុភមង្គលដល់គ្រួសាររបស់គាត់ទៀតផង ។ និយាយជារួម វប្បធម៌ខ្មែរយើង គោរពនារី ផ្តល់តម្លៃចំពោះនារី យកនារីជាធំនៅក្នុងសង្គមនិងគ្រួសារ ព្រមទាំងបានចាត់ទុក នារីជាមាតានៃប្រទេសជាតិតាំងពីយូរលង់ណាស់មកហើយ តាមរយៈពាក្យបុរាណពោលថា **"មេទ័ព" "មេបា"** និង **"មាតុភូមិ ឬ មាតុប្រទេសកម្ពុជា"** ជាដើម ។ ជាទូទៅ ស្ត្រីគឺជាមាតាដ៏ល្អ និងជាមេផ្ទះដ៏ប្រពៃ ដែលចេះថែទាំអប់រំកូនឱ្យក្លាយជាពលរដ្ឋល្អ ។

បច្ចុប្បន្ន តាមរយៈការងារកាកបាទក្រហមកម្ពុជា ក្រោមការដឹកនាំរបស់ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** ប្រធានកាកបាទក្រហមកម្ពុជា និងការខិតខំប្រឹងប្រែងរបស់សម្តេច ក្នុងការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ពិសេសមកលើស្ត្រីនិងកុមារ ការធ្វើអាជីវកម្មផ្លូវភេទ ការប្រយុទ្ធប្រឆាំងគ្រឿងញៀន និងជួយកុមារកំព្រាជាដើម ធ្វើឱ្យបុត្រធីតា និងយុវវ័យមានឱកាសចូលរួមចំណែកទទួលខុសត្រូវ លើរាល់សកម្មភាពក្នុងគ្រួសារ និងសង្គម ក៏ដូចជាទទួលបានការអប់រំ ការកសាង និងការពង្រឹងសមត្ថភាពខ្លួនឯង សំដៅធ្វើខ្លួនឱ្យក្លាយទៅជាកូនល្អ មិត្តល្អ សិស្សល្អ មិនប្រើអំពើហិង្សា មិនសេពគ្រឿងញៀន រួមចំណែកធានាសណ្តាប់ធ្នាប់សង្គម និងចូលរួមអភិវឌ្ឍជាតិមាតុភូមិជាទីស្នេហារបស់យើង បានធ្វើឱ្យតម្លៃស្ត្រី និងសីលធម៌សង្គម ត្រូវបានលើកតម្កើងជាលំដាប់ ទាំងក្នុងវេទិកាជាតិ និងអន្តរជាតិ ។ ខ្ញុំសង្កេតឃើញថា បច្ចុប្បន្ន ស្ត្រីចេះអភិវឌ្ឍនិងលើកកម្ពស់ខ្លួនឯង ដើម្បីចូលប្រឡូកក្នុងគ្រប់កិច្ចការសង្គម ចាប់តាំងពីកម្មកររហូតដល់មានឋានៈ និងតួនាទីខ្ពស់ នៅក្នុងជួររដ្ឋាភិបាល រដ្ឋសភា និងព្រឹទ្ធសភាជាដើម ។

ដោយឡែក នៅធនាគារជាតិនៃកម្ពុជាយើងវិញបច្ចុប្បន្ន មានមន្ត្រីបុគ្គលិកសរុបទូទាំង ប្រទេសចំនួន ១.៣៦៤នាក់ ក្នុងនោះថ្នាក់ដឹកនាំ និងមន្ត្រីបុគ្គលិកជានារីមានចំនួន ៦១៤នាក់ ។ ចំនួននេះបញ្ជាក់ថា សមាមាត្រមន្ត្រីបុគ្គលិកជាស្ត្រី ចាប់តាំងពីថ្នាក់ទេសាភិបាលរហូតដល់ បុគ្គលិកធម្មតា កើនដល់ ៤៥% នៃចំនួនសរុប ។ ស្ត្រីនៅធនាគារជាតិនៃកម្ពុជាភាគច្រើន ទទួលខុសត្រូវលើការងារដឹកនាំនិងគ្រប់គ្រង ការងារ

ជំនាញបច្ចេកទេស និងការងារប្រតិបត្តិការ ជាដើម ។ សមាមាត្រដ៏ធំនេះ បានបង្ហាញឱ្យឃើញអំពីសមត្ថភាព ការលើកកម្ពស់ស្ត្រី និងសារៈសំខាន់របស់ស្ត្រីចំពោះការងារ ព្រមទាំងមានការជឿជាក់ក្នុងការបំពេញតួនាទីភារកិច្ច នៅគ្រប់លំដាប់ថ្នាក់នៃការគ្រប់គ្រងធនាគារ ។

**- គណៈអធិបតី ជាទីគោរព !**

**- បងប្អូននារីទាំងអស់ ជាទីស្នេហា !**

ពីមួយអាណត្តិ ទៅមួយអាណត្តិ រាជរដ្ឋាភិបាល កាន់តែយកចិត្តទុកដាក់ និងទទួលស្គាល់នូវសមត្ថភាព និងសក្តានុពលរបស់ស្ត្រីក្នុងការ អភិវឌ្ឍសេដ្ឋកិច្ចជាតិ ។ ជាក់ស្តែង រាជរដ្ឋាភិបាលកម្ពុជាក៏បានបង្កើតផែនការយុទ្ធសាស្ត្រនារីរតនៈ ដើម្បីជម្រុញការចូលរួមរបស់ស្ត្រីនៅក្នុងការងារសង្គមនិងនយោបាយ និងលើកកម្ពស់ផ្នែកសុខភាពស្ត្រី រួមទាំងការអប់រំស្ត្រីនិងក្មេងស្រី និងដើម្បីដោះស្រាយបញ្ហានៅក្នុងសង្គម និងការផ្សព្វផ្សាយនូវរូបភាពអសីលធម៌ ។ល។ ម្យ៉ាងទៀត តាមរយៈយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា រាជរដ្ឋាភិបាលក៏បានយកចិត្តទុកដាក់ក្នុងការកាត់បន្ថយគម្លាតយេនឌ័រនៅគ្រប់វិស័យ ដោះស្រាយនូវបញ្ហាប្រឈមទាំងឡាយដែលរារាំងដល់ស្ត្រី និងបង្កឱកាសគ្រប់បែបយ៉ាងដល់ស្ត្រី ដើម្បីឱ្យស្ត្រីអាចចូលរួមក្នុងកិច្ចអភិវឌ្ឍបានពេញលេញ ។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលបន្តអនុវត្តគោលការណ៍ផ្តល់ឥណទានខ្នាតតូច និងមធ្យម ដល់ស្ត្រីដើម្បីបង្កើតមុខរបរចិញ្ចឹមជីវិត ។ ជាក់ស្តែង ស្ត្រីភាគច្រើនបានទទួលឥណទានខ្នាតតូចនិងមធ្យម និងបានដើរតួនាទីសំខាន់ក្នុងការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ឥណទាន ទាំងនោះក្នុងការប្រកបរបរចិញ្ចឹមជីវិតទទួលបានប្រសិទ្ធភាពខ្ពស់ ។ តួនាទីស្ត្រីគឺជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចនិងសង្គមជាតិ ។ ទន្ទឹមនេះ ការប្រារព្ធទិវាអន្តរជាតិនារី ៨ មីនា នៅឆ្នាំ២០១៥ នេះ មិនត្រឹមតែរំឭកឡើងវិញនូវខួបលើកទី១០៤ នៃការទទួលបានសិទ្ធិសេរីភាពរបស់ស្ត្រីស្មើនឹងបុរសប៉ុណ្ណោះទេ ថែមទាំងដើម្បីរំឭកខួបទី៣៤ នៃសន្ធិសញ្ញាលុបបំបាត់នូវរាល់ការរើសអើងចំពោះស្ត្រី ខួបទី១៩ នៃសន្និសីទពិភពលោកស្តីពីស្ត្រី និងខួបទី១១ នៃគោលដៅអភិវឌ្ឍសហស្សវត្សផងដែរ ។

តាមរយៈប្រធានបទប្រចាំឆ្នាំ២០១៥ នេះ ក៏បានស្តែងឲ្យឃើញពីសមិទ្ធផលនានាដែលកើតមានក្នុងរយៈពេល ២០ឆ្នាំ មកនេះក្រោយពីសន្និសីទស្ត្រីពិភពលោកឆ្នាំ១៩៩៥ និងធ្វើការបំផុសកៀរគរប្រជាពលរដ្ឋកម្ពុជាឲ្យធ្វើការរួមគ្នា ដើម្បីឈានទៅសម្រេចបាន

នូវសមភាពយេនឌ័រពិតប្រាកដរវាងបុរស និងស្ត្រី ។ ក្នុងរយៈពេល ២០ឆ្នាំ កន្លងមកនេះ ស្ត្រីនៅកម្ពុជា បានចូលរួមយ៉ាងសកម្ម ដើម្បីធ្វើការអភិវឌ្ឍន៍សង្គមលើគ្រប់វិស័យសំខាន់ លើវិស័យសេដ្ឋកិច្ច និងនយោបាយ និងការធ្វើសេចក្តីសម្រេច ដូចជាអាត្រាចូលរួម របស់ស្ត្រី ជាថ្នាក់ដឹកនាំនៅថ្នាក់ជាតិនិង ថ្នាក់ក្រោមជាតិ ប្រមាណ ៣៧% ជាស្ត្រី ។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណចំពោះលោកជំទាវ ឯកឧត្តម លោក លោកស្រី និងនាងកញ្ញាទាំងអស់ ដែលបានចូលរួមក្នុងពិធីយើងថ្ងៃនេះ និងសូមជូនពរឱ្យជួបប្រទះ តែពុទ្ធពរទាំង ៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

**សូមអរគុណ!**